# មិនយកខ្មែរណាជាសត្រូវ ?

សំនួរនេះ សមនឹងលើកយកមកពិចារណា ក្នុងគំនិត រកការពិត អំពី វិសាលភាពនយោបាយ របស់វានៅស្រុកខ្មែរ។ ពាក្យស្លោកនេះ មានគោលដៅ នយោបាយជាឧត្តមគតិ ដើម្បីបង្ហាញ នូវគោលការណ៍ នៃសីលធម៌សង្គម ដែលអ្នកប្រកាសប្រកាន់យកចំពោះមុខគូប្រឆាំងរបស់ខ្លួន។ ពាក្យសត្រូវ នៅក្នុងបរិបទខ្មែរ គឺជាចម្លើយចំពោះអំពើ របស់គណបក្សកាន់អំណាច ដែលទុកអ្នកប្រឆាំងនឹងខ្លួន ជាសត្រូវដាច់មុខ ហើយធ្វើគ្រប់មធ្យោបាយទុច្ចរិត ដើម្បីយកឈ្នះជាដាច់ខាត។ ដូច្នេះប្រយោគ « មិនយកខ្មែរណាជាសត្រូវ » គឺប្រកាសឡើង នៅក្នុងស្មារតី អោយមាន ការផ្លាស់ប្តូរអ្នកដឹកនាំតាមសន្តិវិធី ពោលថា សត្រូវនយោបាយក៏ជាខ្មែរ ហើយខ្មែរនិងខ្មែរ មិនមែនជាសត្រូវនឹងគ្នានោះឡើយ។ តែនៅស្រុកខ្មែរគ្មាននីតិរដ្ឋ មានអ្នកទោសមនសិការ, ឃាតកម្ម និង អ្នកទោសនយោបាយ ដែលជាទង្វើដោយជាក់របស់ពួកអ្នកកាន់អំណាចផ្តាច់ការ, សួរថា តើនៅក្នុងស្មារតី « មិនយកខ្មែរណាជាសត្រូវ » ជាការលើកទោសចំពោះឃាតករ ដោយប្រើ អំពើកុសល ឆ្លើយនឹងអកុសល ? ត្រូវគិតថា មានភាពធូររលុង នៅចំពោះអំពើនេះ វាជាអសីលធម៌។ ដូច្នេះយុត្តិធម៌ ត្រូវមានតុលាការឯករាជ្យ ហើយផ្តល់សេរីភាពដល់ជនរងគ្រោះ អាចមានសិទ្ធិ រកយុត្តិធម៌តាមផ្លូវច្បាប់។ គ្រប់ការសម្រុះសម្រួលនយោបាយ គ្មានយុត្តិធម៌ជាមូលដ្ឋាន គឺជាឧក្រិដ្ឋកម្ម៕